# ក្រុមមេធាវីការពារក្តី អៀង សារី
# IENG SARY DEFENCE TEAM
# EQUIPE DE DEFENSE DE IENG SARY

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 22-Jun-2012, 16:00
CMS/CFO: Sann Rada

**អាង ឧត្តម និង Michael G. KARNAVAS**

**សហមេធាវីការពារក្តី អៀង សារី**

ថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០១២

ជូន: លោកស្រី Susan LAMB
**មន្ត្រីច្បាប់ជាន់ខ្ពស់**
**អង្គជំនុំជម្រះសាលាដំបូង,អវតក**

ចម្លងជូន: **ក្រុមមេធាវីការពារក្តី**
**ការិយាល័យសហព្រះរាជអាជ្ញា**
**មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

កម្មវត្ថុ: **សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំរបស់លោក អៀង សារី អនុលោមតាមវិធាន៨៧ (៤) ទាក់ទងនឹងឯកសារដែលនឹងយកមកប្រើក្នុងអំឡុងពេលចោទសួរអ្នកជំនាញ David Chandler (E172/24/4)**

លោកស្រី Lamb ជាទីរាប់អាន :

ថ្ងៃនេះ យើងខ្ញុំបានទទួលដំណឹងអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់យើងខ្ញុំទាក់ទងនឹងឯកសារជាក់លាក់មួយចំនួនដែលនឹងយកមកប្រើក្នុងអំឡុងពេលចោទសួរអ្នកជំនាញ David Chandler ។ កថាខណ្ឌទី៦ នៃសេចក្តីសម្រេចនេះលើកឡើងថា :

> អង្គជំនុំជម្រះសាលាដំបូង កត់សម្គាល់ថា ដូចដែលបានរៀបរាប់កម្អិតក្នុងសំណើសុំ E172/24/3 ឥឡូវនេះ ឯកសារ (ក)ដល់(គ) មិនមាននៅក្នុងសំណុំរឿងឡើយ ។ ទោះបីជាក្រុមមេធាវីការពារក្តី លោក អៀង សារី បានស្នើសុំឲ្យមានការបកប្រែឯកសារទាំងនេះក៏ដោយ មកទល់ពេលនេះ

> ទាំងអង្គជំនុំជម្រះសាលាដំបូង និងភាគីដទៃទៀត ពុំទាន់អាចរកបានសំណៅនៃឯកសារទាំងនេះនៅឡើយទេ។ ជាងនេះទៅទៀត ឯកសារ **ក** អាចរកបានជាសារធារណៈចាប់តាំងពីឆ្នាំ១៩៨៩, ឯកសារ **ខ** ចាប់តាំងពីឆ្នាំ ១៩៩៤ និងឯកសារ **គ** ចាប់តាំងពីឆ្នាំ ២000 មកម្លេះ ។ ទោះបីជាប្រភពទាំងនេះមិនឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវដែលមានចែងក្នុងវិធាន ៨៧ (៤) ហើយដូច្នេះមិនអាចត្រូវបានទទួលយកជាឯកសារថ្មីក៏ដោយ អង្គជំនុំជម្រះសាលាដំបូង មិនបានជំទាស់ក្រុមមេធាវីការពារក្តីលោក អៀង សារី ក្នុងការប្រើប្រាស់ខ្លឹមសារនៃឯកសារទាំងនោះនៅពេលរៀបចំសំណួរដើម្បីចោទសួរអ្នកជំនាញឡើយ ក្នុងករណីដែលមានភាពពាក់ព័ន្ធ ប្រសិនបើសំណៅឯកសារដែលផ្តល់ឲ្យតាមការស្នើសុំជាមុនដោយទាន់ពេលវេលាទាំងនេះ ត្រូវបានផ្តល់ជូនអង្គជំនុំជម្រះសាលាដំបូង និងភាគីដទៃទៀត។

វាជារឿងត្រឹមត្រូវដែលឯកសារទាំងបីនេះពុំអាចរកបាននៅក្នុងសំណុំរឿងព្រោះវាជាឯកសារថ្មី។ ប៉ុន្តែវាមិនមែនជារឿងត្រឹមត្រូវទេដែលថាអង្គជំនុំជម្រះសាលាដំបូង ឬ ភាគី មិនអាចរកឯកសារទាំងនេះបាន ។ កាលពីថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១២[1] យើងបានឲ្យគេដាក់ឯកសារទាំងនេះនៅក្នុងប្រព័ន្ធផ្ទុកឯកសាររួមមុនពេលយើងធ្វើសំណើសុំនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២ ដើម្បីដាក់ឯកសារទាំងនេះនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[2]។ នៅក្នុងសំណើសុំនោះ យើងបានផ្តល់លេខ ERNs របស់ឯកសារនីមួយៗ ហើយបានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង និងភាគីថា ឯកសារទាំងនេះអាចរកបាននៅក្នុងប្រព័ន្ធផ្ទុកឯកសាររួម។ នេះជាអ្វីដែល កសព ធ្លាប់ធ្វើនៅពេលខ្លួនដាក់ឧបសម្ព័ន្ធឯកសារថ្មី។ កសព មិនបានយកសំណៅឯកសារទៅឲ្យភាគីទាំងអស់ដោយផ្ទាល់ដៃឡើយ ប៉ុន្តែ កសព បានដាក់ឯកសារទាំងនោះនៅក្នុងប្រព័ន្ធផ្ទុកឯកសារួមដោយផ្តល់លេខ ERN នៅក្នុងឧបសម្ព័ន្ធរបស់វា[3] ។ តាមពិតទៅ កសព "បានស្នើឲ្យភាគីផ្តួចផ្តើមគំនិតដើម្បីដាក់ឯកសារថ្មីៗរបស់ពួកគេទៅក្នុងប្រអប់ (folder) នៅក្នុងប្រព័ន្ធផ្ទុកឯកសាររួម"[4] ។

---

[1] ការបញ្ជាក់អះអាងតាមសារអេឡិចត្រូនិចពីផ្នែកគ្រប់គ្រងតុលាការអំពីការដាក់ឯកសាររបស់ពួកគេទៅក្នុងប្រព័ន្ធផ្ទុកឯកសាររួមទៅកាន់ក្រុមមេធាវីការពារក្តីលោក អៀង សារី គឺអាចរកបានតាមការស្នើសុំ។

[2] សំណើរបស់ អៀង សារី អនុលោមតាមវិធាន៨៧ (៤) ទាក់ទងនឹងឯកសារដែលអាចនឹងយកទៅប្រើក្នុងអំឡុងពេលចោទសួរអ្នកជំនាញ David Chandler, ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២, ឯកសារ E172/24/3។

[3] សូមមើល, ឧទាហរណ៍, បញ្ជីឯកសាររបស់ កសព E9/31.21។

[4] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាទៅកាន់អង្គជំនុំជម្រះសាលាដំបូង និងភាគី ពាក់ព័ន្ធនឹងការពិនិត្យឯកសារថ្មីៗដែលបានចុះក្នុងបញ្ជីឯកសាររបស់ កសព E9/31.21, E109/4.1, E131/1/4.1, ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១១, ឯកសារ E190។

អង្គជំនុំជម្រះសាលាដំបូង បានកត់សម្គាល់ឃើញថាឯកសារដែលយើងខ្ញុំបានស្នើសុំ "មិនបានឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវដែលមានចែងក្នុងវិធាន៨៧ (៤) នៃវិធានផ្ទៃក្នុងឡើយ" ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូង មិនបានផ្តល់ហេតុផលចំពោះការយល់ឃើញបែបនេះរបស់ខ្លួនឡើយ។ វានឹងជួយយើងខ្ញុំ និងភាគីទាំងអស់បានច្រើនណាស់ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង អាចពន្យល់ថាតើហេតុអ្វីបានជាលោក *មិន* ចាត់ទុកឯកសារទាំងនេះថាបានបំពេញលក្ខខណ្ឌតម្រូវរបស់វិធាន៨៧ (៤) ជាពិសេសនៅពេលដែលវិធាន៨៧ (៤) គ្រាន់តែតម្រូវថា: **ក.** ភស្តុតាងត្រូវឆ្លើយតបទៅនឹងខ្លឹមសារនៃវិធាន៨៧ (៣) នៃវិធានផ្ទៃក្នុង និង **ខ.** ភាគីដែលស្នើសុំត្រូវបង្ហាញថាភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះតែប៉ុណ្ណោះ។ នៅក្នុងន័យនេះ ការពិនិត្យពិច័យដ៏ជាក់លាក់មួយបង្ហាញថាក្រុមមេធាវីការពារក្តីលោក អៀង សារី បានឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវទាំងពីរនៃវិធាន៨៧ (៤) ដូច្នេះ ករណីនេះស្នើសុំឲ្យមានការបញ្ជាក់ឲ្យបានច្បាស់ និងការណែនាំបន្ថែមទៀត ។ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា "សញ្ញាណនៃ "ការអាចរកបាន" នៃភស្តុតាង មានទំនាក់ទំនងទៅនឹងការបំពេញការងារដោយយកចិត្តទុកដាក់ពិតប្រាកដ[5]"។ សំណើរបស់យើងខ្ញុំបានពន្យល់ថា សាស្ត្រាចារ្យ Chandler បានចាប់ផ្តើមសរសេរអំពីប្រវត្តិសាស្ត្រកម្ពុជា យ៉ាងហោចណាស់ចាប់តាំងពីដើមទសវត្សឆ្នាំ១៩៧០ មកម្ល៉េះ ហើយបាននិពន្ធឯកសារប្រភេទនេះជាច្រើនរួមទាំងការសរសេរជាសៀវភៅ អត្ថបទ សុន្ទរកថា និក្ខេបបទថ្នាក់បណ្ឌិតរបស់គាត់ និងបានចុះផ្សាយលើគេហទំព័រថែមទៀតផង ។ វាត្រូវចំណាយពេលវេលាច្រើនណាស់ដើម្បីស្វែងរក និងប្រមូល ឯកសារទាំងនេះដែលភាគច្រើនត្រូវបានសរសេរមុនពេលពេលមានការប្រើប្រាស់បច្ចេកវិទ្យាកុំព្យូទ័រយ៉ាងទូលំទូលាយ ហើយបើតាមយើងខ្ញុំដឹង ឯកសារទាំងនោះ នៅតែជាឯកសារជាសំណៅប៉ុណ្ណោះទេ។ ដូច្នេះ យើងខ្ញុំត្រូវបានគេតម្រូវឲ្យពិនិត្យឯកសារនេះដើម្បីស្វែងរកភាពពាក់ព័ន្ធរបស់វា។ ជាច្រើនមលើកច្រើនសារមកហើយ ភាពពាក់ព័ន្ធរបស់ឯកសារជាក់លាក់មួយ បានបង្ហាញឲ្យឃើញច្បាស់តែបន្ទាប់ពីពេលដែលឯកសារនោះ ត្រូវបានពិនិត្យដោយផ្អែកលើខ្លឹមសារពាក់ព័ន្ធរបស់វាជាមួយនឹងឯកសារដៃទៀតតែប៉ុណ្ណោះ។ ទោះបីជាឯកសារទាំងនេះ កើតឡើងមុនពេលចាប់ផ្តើមជំនុំជម្រះក៏ដោយ ប៉ុន្តែនៅពេលនោះ យើងខ្ញុំពុំបានដឹងឡើយ ហើយក៏គ្មានឯកសារនោះដែរ ទោះបីជាយើងខ្ញុំបានបំពេញការងារដោយយកចិត្តទុកដាក់យ៉ាងណាក៏ដោយ។ ដូច្នេះ យើងខ្ញុំសូមអះអាងដោយក្តីគោរពថា ឯកសារទាំងនេះ ពុំអាចរកបាន ស្របតាមខ្លឹមសារនៃវិធាន៨៧ (៤)។

យើងនឹងខ្ញុំនឹងទទួលយកការអះអាងនេះដែលយើងសង្ឃឹមថានឹងជួយលុបបំបាត់បន្ថែមទៀតនូវគំនិតដែលថា អង្គជំនុំជម្រះសាលាដំបូង កំពុងអនុវត្តបទដ្ឋានដ៏តឹងរឹងគ្មានការបទបែនទាក់ទងនឹងការប្រើប្រាស់ឯកសារ

[5] សេចក្តីសម្រេចទាក់ទងនឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត, ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១២, ឯកសារ E151។

ដែលអាចនាំទៅដល់ការរំលោភឆន្ទានុសិទ្ធិរបស់ខ្លួន។ ដើម្បីឲ្យមានភាពស៊ីសង្វាក់គ្នា និងដើម្បីឲ្យមានសមធម៌ យើងខ្ញុំក៏សូមគូសបញ្ជាក់ផងដែរថា នៅពេលថ្មីៗនេះ អង្គជំនុំជម្រះសាលាដំបូង បានទទួលយកសៀវភៅមួយក្បាលដែលដាក់ជូនដោយ កសព ទោះបីជាសហព្រះរាជអាជ្ញា "ខកខានមិនបានពន្យល់ពីមូលហេតុដែលពួកគេពុំអាចទទួលបានសៀវភៅនេះតាមរយៈការអនុវត្តដោយយកចិត្តទុកដាក់ សមស្របមុនពេលបណ្ណាល័យ អវតក ទទួលបានសៀវភៅនេះ និងមុនពេលបើកសវនាការ[6] ក៏ដោយ"។ ពិតណាស់ការប្រព្រឹត្តមិនស្មើភាពគ្នាចំពោះភាគី មិនបានគាំទ្រដល់ការគិតដែលជៀសមិនរួចអំពីវិសមភាពឡើយ ហើយអង្គជំនុំជម្រះតុលាការកំពូលក៏ធ្លាប់បានបញ្ជាក់យ៉ាងច្បាស់អំពីករណីនេះដែរ ទោះបីជាក្នុងបរិបទខុសគ្នាក៏ដោយ[7]។

សូមលោកស្រីទទួលយកលិខិតនេះដោយក្តីរាប់អានអំពីយើងខ្ញុំ។

**ANG Udom** **Michael G. KARNAVAS**

Co-Lawyers for Mr. IENG Sary

[6] ដូចជើងទំព័រខាងលើ, កថាខណ្ឌទី ៣២។

[7] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីបណ្តឹងជិតចិត្តលោកស្រីចៅក្រម Silvia Cartwright, ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២, ឯកសារ E137/5/1/3, កថាខណ្ឌទី២៤។